**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាលខេត្តឧត្តរមានជ័យ**
លេខ: ០០១ សជណ.ឧជ

ឧត្តរមានជ័យ,ថ្ងៃទី ០៤ ខែមករា ឆ្នាំ២០១៣

# សេចក្តីជូនដំណឹង
## ស្តីពីការបង់ពន្ធប៉ាតង់សម្រាប់ឆ្នាំ ២០១៣

**យោង:** -ក្រឹត្យច្បាប់លេខ ២២ ក្រច. ចុះថ្ងៃទី១៤ ខែ មិថុនា ឆ្នាំ ១៩៨៥ ស្តីពីពន្ធប៉ាតង់ និង មាត្រា៣៩ នៃច្បាប់ហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១១ ន.ស៩៤ ចុះថ្ងៃទី៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤។

-សារាចរណែនាំលេខ ០០៤ សហវ. ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០៧ របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ស្តីពីការអនុវត្តន៍ពន្ធប៉ាតង់។

រដ្ឋបាលខេត្ត សូមជូនដំណឹងដល់បងប្អូនអាជីវករ និង ក្រុមហ៊ុនទាំងអស់ដែលបាន និង កំពុងប្រកបអាជីវកម្ម នៅក្នុងខេត្ត អោយបានជ្រាបថា:

១-ការបង់ពន្ធប៉ាតង់សម្រាប់ឆ្នាំ ២០១៣ ត្រូវចាប់ផ្តើមអនុវត្តពីថ្ងៃទី ០១ មករា ដល់ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១៣។

២-អាជីវកម្មដ្ឋាន ដែលប្រកបមុខរបរច្រើនប្រភេទ ត្រូវបង់ពន្ធប៉ាតង់ផ្សេងៗគ្នា ទៅតាមមុខរបរនីមួយៗ។

៣-អាជីវកម្មដ្ឋាន ដែលមានសាខានៅខេត្តផ្សេងគ្នា ត្រូវបង់ពន្ធប៉ាតង់នៅខេត្ត ដែលខ្លួនកំពុងស្ថិតនៅ។

៤-ករណីមានការផ្លាស់ប្តូរទីកន្លែងទៅខេត្តផ្សេង រឺ ផ្លាស់ប្តូរមុខរបរថ្មី ត្រូវបង់ពន្ធប៉ាតង់ជាថ្មីម្តងទៀត ។ ពេលឈប់ប្រកបអាជីវកម្ម ត្រូវប្រគល់ប័ណ្ណប៉ាតង់នោះ មកអង្គភាពពន្ធដារវិញ។

៥-អ្នកជាប់ពន្ធដែលចូលរួមដេញថ្លៃ ពិគ្រោះថ្លៃ រឺ ស្នង់ថ្លៃ អាចប្រើប្រាស់បណ្ណប៉ាតង់ដែលបានបង់ពន្ធរួចហើយ ដើម្បីបំពេញបែបបទចូលរួម ដេញថ្លៃ ពិគ្រោះថ្លៃ រឺ ស្នង់ថ្លៃ តែបណ្ណប៉ាតង់នោះត្រូវមានមុខរបរដូចគ្នា។

*<u>ករណីទី១</u> : អ្នកជាប់ពន្ធមកពីខេត្តផ្សេង ដែលជាប់ពន្ធតាមរបបស្វ័យប្រកាស និងអ្នកជាប់ពន្ធតាមរបបម៉ៅការ ត្រូវបង់ពន្ធជាថ្មី ក្រោយពេលដេញថ្លៃ ពិគ្រោះថ្លៃ រឺ ស្នង់ថ្លៃបាន ។ បើអ្នកជាប់ពន្ធទទួលការបានច្រើនកន្លែង ក្នុងខេត្តតែមួយលើមុខរបរដូចគ្នានោះទឹកប្រាក់ដែលបង់បន្តបន្ទាប់ មិនអោយលើសពី១.១៤០.០០០៛ ឡើយ ក្នុងឆ្នាំតែមួយ។

ចំពោះអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស ទោះបីទឹកប្រាក់ទទួលការមានកម្រិតណាក៏ដោយក៏ត្រូវរក្សាអត្តសញ្ញាណជាប់ពន្ធតាមរបបស្វ័យប្រកាសដដែល នៅក្នុងបណ្ណប៉ាតង់ជាបន្តបន្ទាប់។

*<u>ករណីទី២</u> : អ្នកជាប់ពន្ធក្នុងខេត្តតាមរបបស្វ័យប្រកាស និង អ្នកជាប់ពន្ធតាមរបបម៉ៅការ ដែលបានបង់ពន្ធមុខរបរដូចគ្នាគ្រប់ចំនួន ១.១៤០.០០០៛ហើយ មិនត្រូវបង់ពន្ធទៀតទេ។ ប៉ុន្តែបើទឹកប្រាក់បង់ពន្ធរួច មានចំនួនតិចជាង ១.១៤០.០០០៛ នោះត្រូវបង់ពន្ធថែមតាមផលរបរ ដែលកើតមានបន្តបន្ទាប់ក្នុងឆ្នាំតែមួយ ដោយមិនអោយលើសពីចំនួនខាងលើ។

៦-ករណីមិនបានបង់ពន្ធ រឺ គេចវេសមិនបង់ពន្ធ រឺ ក្លែងបន្លំបណ្ណប៉ាតង់ ត្រូវទទួលទោសដូចមានចែងក្នុងបទបញ្ញត្តិ ស្តីពីសារពើពន្ធ។ អ្នកជាប់ពន្ធត្រូវដាក់តាំង រឺ ព្យួរបណ្ណប៉ាតង់ នៅទីកន្លែងប្រកបអាជីវកម្មរបស់ខ្លួន។

អភិបាលខេត្តសង្ឃឹមយ៉ាងមុតមាំថា បងប្អូនអាជីវករ និង ក្រុមហ៊ុនទាំងអស់ ប្រាកដជាមានស្មារតីភ្ញាក់រលឹកខ្ពស់ ទៅបំពេញកាតព្វកិច្ចបង់ពន្ធប៉ាតង់សម្រាប់ឆ្នាំ ២០១៣នេះ បានគ្រប់គ្រាន់ទាន់ពេលវេលាជាពុំខានឡើយ។

**អភិបាលខេត្ត**

ប៊ិច_សុខិន

**ចម្លងជូន:**
-ក្រសួងមហាផ្ទៃ
-អគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
-សាខាពន្ធដារខេត្ត "ដើម្បីអនុវត្ត"
-ស្ថានីយទូរទស្សន៍ខ្សែកាប និង វិទ្យុ "ដើម្បីផ្សព្វផ្សាយ"
-ឯកសារ-កាលប្បវត្តិ